ក

# មាតិកា

## I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១២-១០-២០១១-ព្រះរាជក្រឹត្យ នស/រកត/១០១១/៩៣៣ ស្តីពីការតែងតាំង លោក ចាន់ ឆៀវហាន ជា ឧកញ៉ា ៧៨៧១

២០-១០-២០១១-ព្រះរាជក្រឹត្យ នស/រកត/១០១១/៩៣៤ ស្តីពីការតែងតាំង លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការ ជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច ៧៨៧២


## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ


១៨-១០-២០១១-អនុក្រឹត្យលេខ ២៣២ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៧៨៧៣

១៨-១០-២០១១-អនុក្រឹត្យលេខ ១១១៧ អនក្រ.តត ស្តីពី ការកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាល នៃ សាលាភូមិន្ទរដ្ឋបាល ៧៨៧៥

១៨-១០-២០១១-អនុក្រឹត្យលេខ ១១១៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៨៧៧

១៨-១០-២០១១-អនុក្រឹត្យលេខ ១១១៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧៨៧៨

១៨-១០-២០១១-អនុក្រឹត្យលេខ ១១២០ អនក្រ.តត ស្តីពី ការលុបឈ្មោះទីប្រឹក្សា ក្រសួងការពារជាតិ ៧៨៧៩

១៩-១០-២០១១-អនុក្រឹត្យលេខ ១១២១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៨៨០

១៩-១០-២០១១-អនុក្រឹត្យលេខ ១១២២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧៨៨២


### ២.សេចក្តីសម្រេច


១៨-១០-២០១១ -សេចក្តីសម្រេចលេខ ៥៧ សសរ ស្តីពី ការបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ៧៨៨៤


## III.ការងារបណ្តាក្រសួង

### ១.ទីស្តីការដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


២១-៩-២០១១ -ប្រកាសលេខ ៨៦៨ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឌីស៊ែល (ខេមបូឌា) បង្កើតរោងចក្រ ផលិតថ្នាំលាបការពារកំដៅ ៧៨៨៧

២១-៩-២០១១ -ប្រកាសលេខ ៨៦៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ញូ អេស អឹកែរៃ បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧៨៩១

២១-៩-២០១១ -ប្រកាសលេខ ៨៧០ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេម ហ្វអេវើ បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧៨៩៥

## ២-ឧីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៨-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៥៥០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្ស៊ី ខូខ គូខ សេន អ៊ិនខេសមេន** ៧៨៩៩

២៨-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៥៥១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នំពេញ ម្រេាស មីសិន** ៧៩០១

២៨-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៥៥២ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ណាំបើ ច័ន អ៊ិនធើណេសិនណល ឌីវេឡុបមេន យ៉ាញ ស្តុត ខមភេនី** ៧៩០៣

២៨-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៥៥៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **2 ខេ 2 អេស គ្រុប** ៧៩០៥

២៩-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៥៥៨ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែនិង តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **អង្គរ អ៊ីអប៊ី** ៧៩០៧

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៣៣

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

លោក ចាង ឆៀនហាង

ជា

## ឧកញ៉ា

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១១*

៣៦ល. ១១១០.៩៥០

**ក្នុងព្រះបរមនាម និងតាមព្រះរាជឲ្យគ្រាស់បង្គាប់**
**ប្រមុខរដ្ឋស្ដីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ: ៩០១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១
[illegible] រាជរដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៣៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- បានទ្រង់យល់សម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១១ ស្តីពីលទ្ធផលនៃការបោះឆ្នោតទុកចិត្តលើការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល ចំនួន ០១រូប
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងលោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ ជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣៩៤. ១០១០. ៩៥១

លេខ ៥៨៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១
**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

**ស៊យ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញ វត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ១៦៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ជូនក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសាធារណការនិងដឹកជញ្ជូន ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះៈ

ឯកតា:លានរៀល

| ជំពូក | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | និយ័តកម្ម | | ឥណទានថ្មី |
|---|---|---|---|---|---|
| | | | កើន | ថយ | |
| | និយ័តកម្មចេញ | | | | |
| | ៩៩- ឥណទានមិនទាន់បែងចែក | | | | |
| ២១ | អចលកម្មរូបី | ៣១០ ០០០ | | ១៩៨ ០០០ | ១១២ ០០០ |
| | និយ័តកម្មចូល | | | | |
| | ២០- ក្រសួងអភិវឌ្ឍន៍ជនបទ | | | | |
| ២១ | អចលកម្មរូបី | ១០០ ០០០ | ២៨ ០០០ | | ១២៨ ០០០ |
| | ២៥- ក្រសួងសាធារណការនិងដឹកជញ្ជូន | | | | |
| ២១ | អចលកម្មរូបី | ២០៥ ០០០ | ១៧០ ០០០ | | ៣៧៥ ០០០ |

**ប្រការ២.** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ៣.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ១៧ ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
ដូចមាត្រា ៣
ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១១១៧ . អនក្រ . បក**

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាលនៃសាលាភូមិន្ទរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤០ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- យោងតាមសំណើរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១** : ត្រូវបានកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាលនៃសាលាភូមិន្ទរដ្ឋបាល ដូចខាងក្រោម ÷

| | | |
|---|---|---|
| -ឯកឧត្តម **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| -ឯកឧត្តម **ហោថ វឌ្ឍប៊ុនណាត** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| -ឯកឧត្តម **ពេជ្រ ប៊ុនធិន** | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| - ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |

| | | |
|---|---|---|
| - ឯកឧត្តម **ម៉ៅ ហុងលី** | អគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | សមាជិក |
| - ឯកឧត្តម **ជា អឿន** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ឯកឧត្តម **ស៊ុំ ម៉ាប់** | នាយកសាលាភូមិន្ទរដ្ឋបាល | សមាជិកស្ម័យប្រវត្តិ |
| - ឯកឧត្តម **ហោ សុធន** | អគ្គលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - ឯកឧត្តម **ហ៊ាន សាហ៊ីប** | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - ឯកឧត្តម **ច័ន្ទ មនោ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ | សមាជិក។ |

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- មាត្រា ៣
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១១៨ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយ សហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.**

ត្រូវបានបំពាក់មេដាយសហមេត្រី **ថ្នាក់ធិបឌិន្ទ** ជូនដល់ថ្នាក់ដឹកនាំអង្គភាព នៃកងកម្លាំងនគរបាល និងអង្គភាពពាក់ព័ន្ធមួយចំនួន នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម មានសកម្មភាពលេចធ្លោ ក្នុងការទំនាក់ទំនងសំរបសំរួល ដែលធ្វើអោយការអនុវត្តផែនការ សហប្រតិបត្តិការ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងនគរបាលវៀតណាម ឱ្យមានភាពរីកចំរើន និងទទួលបានលទ្ធផលល្អប្រសើរ ជាពិសេសលើវិស័យសន្តិសុខ សណ្តាប់ធ្នាប់ វិស័យបណ្តុះបណ្តាល វិស័យសុខាភិបាល និងការជួយឧបត្ថម្ភផ្នែកបច្ចេកទេស ដូចមានរាយនាមខាងក្រោម ៖

១ លោកវរសេនីយ៍ឯក LE DINH THANH អនុប្រធាននាយកដ្ឋាន A66 នៃអគ្គនាយកដ្ឋានសន្តិសុខក្រៅប្រទេស ក្រសួងនគរបាលវៀតណាម

២ លោកវរសេនីយ៍ឯក QUACH HUU DUNG លេខាទី១ នៃស្ថានទូតវៀតណាមប្រចាំកម្ពុជា

៣ លោកវេជ្ជបណ្ឌិត NGUYEN VAN KHOI នាយករងមន្ទីរពេទ្យចារ៉ៃ

**មាត្រា ២.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១១៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ញៀម គីមសាង** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ ជា**អភិបាលស្រុកកញ្ជ្រៀច** នៃខេត្តព្រៃវែង ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០១១*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១១២០ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការលុបឈ្មោះទីប្រឹក្សា ក្រសួងការពារជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកត /១១៩៧ /០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ ២០០២ ស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១** : ត្រូវបានលុបឈ្មោះលោក ឡឹក ប៊ុនញាណ ទីប្រឹក្សា ក្រសួងការពារជាតិ ដែលមានឋានៈស្មើនឹង អគ្គនាយករង ចេញពីក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនិងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរជននៅក្នុង និងក្រៅប្រទេសចំនួន ១០ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង ស្រះទឹក អគារសិក្សា បណ្ណាល័យ សួនច្បារ ដងទង់ជាតិ ផ្លូវលំ និងឧបត្ថម្ភសំភារៈសិក្សា នៅវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អង្គព្រះស្តេច និងសាលាបឋមសិក្សាអង្គព្រះស្តេច ស្ថិតនៅក្នុងឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ដែលមានរាយនាមដូចខាងក្រោម :

**ក- មេដាយមាសស្ថាបនាជាតិចំនួន ០១ គ្រឿង ផ្តល់ជូន**

| | | |
|---|---|---|
| លោក **ច្រាក់ ប៉ូច** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន១២.០០០ ដុល្លារ |

**ខ- មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៩ គ្រឿង ផ្តល់ជូន :**

| | | |
|---|---|---|
| ១-លោក **ឈើច សុវណ្ណឧុដ** | នាយកវិទ្យាល័យ ហ៊ុន សែន អង្គព្រះស្តេច | ថវិកាចំនួន ៨.៥០០ ដុល្លារ |
| ២-លោក **អន សុខ** | នាយករងវិទ្យាល័យ ហ៊ុន សែន អង្គព្រះស្តេច | ថវិកាចំនួន ៨.២០០ ដុល្លារ |
| ៣-លោក **យិន សុផល** | នាយករងវិទ្យាល័យ ហ៊ុន សែន អង្គព្រះស្តេច | ថវិកាចំនួន ៧.៥០០ ដុល្លារ |
| ៤-លោក **អ៊ុំ ជា** | នាយកសាលាបឋមសិក្សាអង្គព្រះស្តេច | ថវិកាចំនួន ៧.៥០០ ដុល្លារ |

| | | | |
|---|---|---|---|
| ៥-លោក | **សួខ សុផាត** | នាយករងសាលាបឋមសិក្សាអង្គព្រះស្តេច | ថវិកាចំនួន ៧.៣០០ ដុល្លារ |
| ៦-លោក | **ឡៀច គឿន** | ក្រុមប្រឹក្សាឃុំបឹងត្រាញ់ខាងជើង | ថវិកាចំនួន ៧.២០០ ដុល្លារ |
| ៧-លោក | **គួន តៅ** | នាយករងវិទ្យាល័យ ហ៊ុន សែន អង្គព្រះស្តេច | ថវិកាចំនួន ៧.០០០ ដុល្លារ |
| ៨-លោកគ្រូ | **យិន ហោម** | អតីតនាយកសាលាបឋមសិក្សាអង្គព្រះស្តេច | ថវិកាចំនួន ៧.០០០ ដុល្លារ |
| ៩-ឧបាសិកា | **តាំង ម៉ៃថា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៧.០០០ ដុល្លារ |

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តតាកែវ និងសាមីខ្លួនដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ១០ ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៧២ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ១១ គ្រឿង ជូនថ្នាក់ដឹកនាំអង្គការស្មេប ចំនួន ១១រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញបេសកកម្ម លើការងារទំនាក់ទំនង និងស្វែងរកជំនួយ ពីបណ្តាសប្បុរសជនជាតិ និងអន្តរជាតិ ទទួលបានជោគជ័យគួរជាទីមោទនៈ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| 1- | Ms. Anna Feuchtwang | Chief Executive Officer, EveryChild, UK |
| 2- | Mr. Daniel Sweeney | Fundraising Leader, International School of Kuala Lumpur (ISKL Malaysia) and American School in Japan (ASIJ Japan) |
| 3- | Ms. Edith Hanson | Chair of the board, Empowerment for all (EFA Japan) |
| 4- | Mr. Ho Vandy | Managing Director of world Express Tours & Travel, Co-Chair of Tourism Working Group, Chairman of Steering Committee of CATA (Cambodia Association of Travel Agents), Adviser to Cambodia Chamber of Commerce |
| 5- | Ms. Linda Menton | Leader for Project Cambodia, Mont Kiara International School (MKIS Malaysia) |
| 6- | Mr. Phillip T.Thong | Spokesperson, XO Club(USA) |
| 7- | Mr. Shin Se Yong | Chief Executive Officer, United Help for International Children (UHIC Korea) |
| 8- | Mr. Suzuki Hideyuki | Manager, Shinnyo Scholarship Society (SSS Japan) |
| 9- | Mr. Tanaya Minoru | President of Rotary Club of Takahagi, Japan |

| | | |
|---|---|---|
| 10- | Mr. Terumasa Akio | President, Ippan Zaidan Minsai Center B (EDF Japan) |
| 11- | Mr. Teruo Jinnai | Adviser to the Royal Government of Cambodia, former UNESCO Phnom Penh Office |

**មាត្រា ២.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៥៧. សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០១១ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០/អនក្រ/បក ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤/អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ

និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣១/អនក្រ/បក ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈ

-តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១:** បង្កើតគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈមានសមាសភាព ដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម **គាត ឈន់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ជា ចាន់តូ** | ទេសាភិបាលធនាគារជាតិ នៃកម្ពុជា | អនុប្រធាន |
| ៣- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៤- លោកជំទាវ **នាង ចំនួចថាណា** | ទេសាភិបាលរង ធនាគារជាតិ នៃកម្ពុជា | សមាជិក |
| ៥- ឯកឧត្តម **វង្ស វិស្សុត** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម **ចាន់ សុធី** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- លោកស្រី **ខូន សុខា** | អគ្គនាយកបច្ចេកទេស ធនាគារជាតិ នៃកម្ពុជា | សមាជិក |

**ប្រការ២:** គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាល មានមុខងារ និងភារកិច្ចដូចតទៅ:

- រៀបចំ និងត្រួតពិនិត្យការអនុវត្តចក្ខុវិស័យ និងគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈ
- ពិនិត្យយល់ព្រមលើយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ មុននឹងដាក់សុំការសម្រេចពីនាយករដ្ឋមន្ត្រី
- ធ្វើជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលគោលនយោបាយពាក់ព័ន្ធ ដើម្បីធានាឱ្យមានសង្គតិភាពរវាងកិច្ចដំណើរការគ្រប់គ្រងបំណុលសាធារណៈ ជាមួយនឹងគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុ ថវិកា និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ។

**ប្រការ៣:** គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ធ្វើការប្រជុំសាមញ្ញរបស់ខ្លួនក្នុងរយៈពេល ៦ ខែ មួយដង តាមការអញ្ជើញរបស់ប្រធាន ឬអាចប្រជុំញឹកញាប់ជាងនេះ ទៅតាមតម្រូវការចាំបាច់នៃការងារ ។

**ប្រការ៤:** គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចបង្កើតគណៈកម្មការ ឬក្រុមការងារផ្សេងៗទៅតាមការចាំបាច់ ដើម្បីសម្របសម្រួលការរៀបចំ និងតាមដានការអនុវត្តផែនការសកម្មភាពកម្មវិធីនានាពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ។

**ប្រការ៥:** ប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនានា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធដែលមិនមែនជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ឱ្យចូលរួមប្រជុំតាមតម្រូវការចាំបាច់នៃការងារ ។

**ប្រការ៦:** ក្នុងករណីអវត្តមាន សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីចាត់តាំងមន្ត្រីពាក់ព័ន្ធឱ្យចូលរួមប្រជុំជំនួស ។ សមាជិកគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ អាចស្នើសុំការអនុញ្ញាតពីប្រធានគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមន្ត្រីជំនាញដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការងារគ្រប់គ្រងបំណុលសាធារណៈចូលរួមប្រជុំក្នុងឋានៈជាមន្ត្រីជំនួយការ ។

**ប្រការ៧:** គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការបច្ចេកទេសរបស់ខ្លួនក្នុងការបំពេញការងារ ។

**ប្រការ៨:** គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងការបំពេញការងាររបស់ខ្លួន ។

**ប្រការ៩:** រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ១០:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ១០ ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ១០
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ: ៩៦៧៨ ឧរ.ព.អ.ក.ស ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ០៧៦ /១០ ក.ត.ស.ព ចុះថ្ងៃទី១៦.០៧.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ឌីសៃល (ខេមបូឌា) ចុះថ្ងៃទី២៩.០៦.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ឌីសៃល (ខេមបូឌា) តំណាងដោយ លោក HOSOGAI KAZUNORI សញ្ជាតិជប៉ុន អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ TK2585390 ចុះថ្ងៃទី២៧.០៧.២០១០ មានអាសយដ្ឋានបច្ចុប្បន្នៈ No 1-23-17-803 Higashi-magome Ohta-ku Tokyo Japan ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev.4 Code |
|---|---|
| ថ្នាំលាបការពារកំដៅ<br>( Heat Insulation Paints ) | ២០២២ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ៨៥៥ -២៣-២១១១៤១ ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard Khan Daun Penh Phnom Penh Phone 855-23-211141 Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" ឌីសែល (ខេមបូឌា)"*
*"(DISHELLS (CAMBODIA) LTD. )"*

**ទីតាំងរោងចក្រ ៖** *" តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ សង្កាត់ភ្លើងឆេះរទេះ ខណ្ឌដង្កោ រាជធានីភ្នំពេញ និងឃុំគន្ធោក-ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១**: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោម តាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌ ទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២**: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣**: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យ បានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែល ប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

